ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# ឯកសារស្រាវជ្រាវគំរូបច្ចេកទេស
# បង្កាត់ញាស់ត្រីអណ្តែងកូនកាត់



រៀបចំដោយ
**នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)**

ខែឧសភា ឆ្នាំ២០២៦

# អារម្ភកថា

ក្នុងបរិបទដែលវិស័យវារីវប្បកម្មកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមធានានូវសន្តិសុខស្បៀង និងលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ ការចិញ្ចឹមត្រីអណ្ដែងកូនកាត់បានក្លាយជាជម្រើសអាទិភាពមួយសម្រាប់កសិករកម្ពុជា។ ត្រីអណ្ដែងកូនកាត់ គឺជាលទ្ធផលនៃបច្ចេកវិទ្យាបង្កាត់ពូជរវាងត្រីអណ្ដែងអាហ្វ្រិចដែលមានមាឌធំជាមួយនឹងត្រីអណ្ដែងសាច់លឿង ដែលសាច់មានរសជាតិឆ្ងាញ់ និងមានតម្លៃបង្គួរនៅលើទីផ្សារ។ ដើម្បីទទួលបានកូនត្រីដែលមានគុណភាពល្អ ធន់នឹងជំងឺ និងមានអត្រារស់ខ្ពស់ គឺមិនមែនជាការងារដែលត្រូវពឹងផ្អែកលើកត្តាធម្មជាតិទាំងស្រុងនោះទេ ផ្ទុយទៅវិញទាមទារឱ្យមានការយល់ដឹងស៊ីជម្រៅអំពី **"បច្ចេកទេសបង្កាត់ភ្ញាស់បែបសិប្បនិម្មិត"** ដែលជាគន្លឹះដ៏សំខាន់ឈានទៅសម្រេចបានជោគជ័យក្នុងអាជីវកម្មផលិតកូនត្រី។

ឯកសារស្ដីពី " **បច្ចេកទេសបង្កាត់ភ្ញាស់ត្រីអណ្ដែងកូនកាត់** " ត្រូវបានសិក្សាចងក្រងឡើងក្នុងគោលបំណងចែករំលែកចំណេះដឹង ចាប់ពីមូលដ្ឋានគ្រឹះរហូតដល់បច្ចេកទេសស៊ីជម្រៅរួមមាន៖ ការជ្រើសរើសមេបាពូជ ការរៀបចំអាងភ្ញាស់ ការប្រើប្រាស់អ័រម៉ូនឱ្យត្រូវតាមបច្ចេកទេស ការបង្កាត់ ការថែទាំកូនត្រីក្រោយញាស់ឱ្យមានសុខភាពល្អ ការផ្សាំកូនត្រីពូជ និងការប្រមូលផលផងដែរ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងក្លាយជាទុនគំនិតដ៏មានតម្លៃសម្រាប់កសិករ ក៏ដូចជាអ្នកដែលមានបំណងចាប់យកមុខរបរបង្កាត់ពូជត្រីដើម្បីបង្កើនទិន្នផល កាត់បន្ថយការចំណាយលើការទិញពូជពីខាងក្រៅ និងឈានទៅបង្កើតអាជីវកម្មខ្នាតតូច និងមធ្យម។

ក្នុងស្មារតីអភិវឌ្ឍន៍ យើងខ្ញុំរង់ចាំទទួលនូវរាល់មតិកែលម្អក្នុងន័យស្ថាបនាពីសំណាក់កសិករ អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេសពាក់ព័ន្ធទាំងអស់ ដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការកែលម្អឯកសារលើកក្រោយៗទៀតឱ្យកាន់តែសុក្រឹត និងឆ្លើយតបទៅនឹងស្ថានភាពជាក់ស្ដែង។ ឯកសារនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់សក្ដានុពលនៃផលិតកម្មត្រីអណ្ដែងកូនកាត់ក្នុងស្រុក ឆ្លើយតបនឹងតម្រូវការទីផ្សារ និងខ្សែច្រវ៉ាក់ផលិតកម្មកែច្នៃ ក្នុងទិសដៅបង្កើនប្រាក់ចំណូលគ្រួសារ និងរួមចំណែកដល់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តរភាព។

# មាតិកា


១-សេចក្តីផ្តើម ---------- 1
២-លក្ខណៈជីវសាស្ត្រ ---------- 1
២.១. លក្ខណៈរូបរាង ---------- 2
២.២. មជ្ឈដ្ឋានរស់នៅ ---------- 3
២.៣. ចរិតស៊ីចំណី ---------- 4
២.៤. ការលូតលាស់ ---------- 5
២.៥. ការបន្តពូជ ---------- 5
៣-បច្ចេកទេសបង្កាត់ភ្ញាស់ត្រីអណ្តែងកូនកាត់ ---------- 6
៣.១. ការចិញ្ចឹមបំប៉នត្រីមេបា ---------- 6
៣.២. ការជ្រើសរើសត្រីមេបា ---------- 7
៣.៣. ការបង្កាត់បែបសប្បនិម្មិត ---------- 8
៣.៣.១. ការចាក់ថ្នាំអ័រម៉ូន ---------- 8
៣.៣.២. ការវះយកក្រពេញមេជីវិតឈ្មោល ---------- 10
៣.៣.៣. ការច្បូតយកពង ---------- 11
៣.៣.៤. ការបង្កាត់ ---------- 12
៣.៣.៥. ការភ្ញាស់ ---------- 13
៣.៣.៦. ការថែទាំដំបូង ---------- 15
៣.៣.៧. ការប្រមូលកូនត្រីទើបញាស់ ---------- 16
៤. បច្ចេកទេសផ្សាំកូនត្រី ---------- 17
៤.១. ដំណាក់កាលកូនត្រីម្សៅ (Fry) ---------- 17
៤.២. ដំណាក់កាលកូនត្រីពូជ (Fingerling) ---------- 18
៤.៣. ប្រភេទជំងឺ និងការព្យាបាល ---------- 19
៥.ការប្រមូលផលកូនត្រីពូជ ---------- 20
៥.១. ការត្រៀមលក្ខណៈមុនប្រមូលផល ---------- 20
៥.២. បច្ចេកទេសចាប់ និងរាប់ចំនួន ---------- 20
៥.៣. បច្ចេកទេសវេចខ្ចប់ និងដឹកជញ្ជូន ---------- 21
៦-សេចក្តីសន្និដ្ឋាន ---------- 21
ប្រភពឯកសារបានសិក្សាស្រាវជ្រាវ ---------- 22

# ១-សេចក្ដីផ្ដើម

ក្នុងលក្ខខណ្ឌធម្មជាតិ ការបង្កាត់ពូជរវាងត្រីអណ្ដែងអាហ្វ្រិចជាមួយត្រីអណ្ដែងលឿងគឺកម្រកើតមានណាស់ ឬបើកើតមានក៏ផ្ដល់នូវអត្រារស់ទាប និងមិនអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារបានដែរ។ នេះគឺជាមូលហេតុដែល **បច្ចេកទេសបង្កាត់ភ្ញាស់បែបសិប្បនិម្មិត** ដើរតួនាទីជាដំណោះស្រាយដ៏ឆ្លាតវៃ និងមានប្រសិទ្ធភាពបំផុត។

ការបង្កាត់ភ្ញាស់បែបសិប្បនិម្មិតមិនត្រឹមតែជួយសម្រួលដល់ការជួបគ្នារវាងមេបាពូជខុសអម្បូរនោះទេ ប៉ុន្តែវាគឺជាការគ្រប់គ្រងទៅលើកត្តាជីវសាស្ត្រ និងបរិស្ថានក្នុងពេលតែមួយ ដែលដំណើរការនេះតម្រូវឱ្យមានការយល់ដឹងច្បាស់លាស់អំពីវដ្តបន្តពូជក្នុងការកំណត់ពេលវេលាដែលមេពូជមានសមត្ថភាពបន្តពូជល្អបំផុត រួមជាមួយការប្រើប្រាស់បច្ចេកវិទ្យាអ័រម៉ូនដើម្បីរំញោចឱ្យត្រីបញ្ចេញពង និងទឹកកាមស្របតាមពេលវេលាដែលចង់បាន ព្រមទាំងការគ្រប់គ្រងមជ្ឈដ្ឋានភ្ញាស់តាមរយៈការត្រួតពិនិត្យសីតុណ្ហភាព គុណភាពទឹក និងអុកស៊ីសែន ដែលសុទ្ធសឹងជាកត្តាគន្លឹះក្នុងការកំណត់អត្រាញាស់របស់ពងត្រីឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

# ២-លក្ខណៈជីវសាស្ត្រ

ត្រីអណ្ដែងកូនកាត់ (Hybrid Walking Catfish) គឺជាលទ្ធផលនៃការបង្កាត់ពូជរវាងត្រីអណ្ដែងអាហ្វ្រិចឈ្មោល (African Walking Catfish) មានឈ្មោះវិទ្យាសាស្ត្រ Clarias gariepinus និងត្រីអណ្ដែងសាច់លឿងញី (Bighead Walking Catfish) មានឈ្មោះវិទ្យាសាស្ត្រ Clarias macrocephalus ។ ត្រីអណ្ដែងកូនកាត់មានការលូតលាស់លឿន ជាមធ្យមអាចកើនទម្ងន់ពី ១០០ក្រាម-១៥០ក្រាម/ខែ ដែលជួយកាត់បន្ថយរយៈពេលចិញ្ចឹមខ្លីជាងមុន។ ត្រីមានភាពធន់ខ្ពស់ មិនសូវកើតជំងឺ ជាពិសេសជំងឺសើស្បែក និងជំងឺដែលបង្កឡើងដោយប៉ារ៉ាស៊ីត។ ងាយស្រួលចិញ្ចឹមក្នុងបែ អាង តង់ ឬក្នុងស្រះ អាចប្រើប្រាស់ប្រភេទចំណីច្រើនប្រភេទ និងកាកសំណល់ផ្សេងៗពីកសិកម្ម ដែលមិនតម្រូវឱ្យមានបច្ចេកទេសស្មុកស្មាញ។ ត្រីអណ្ដែងកូនកាត់មានតម្លៃសេដ្ឋកិច្ចខ្ពស់ ឆ្លើយតបបានយ៉ាងល្អទៅនឹងតម្រូវការទីផ្សារ។



**ត្រីអណ្ដែងកូនកាត់**
(Hybrid Walking Catfish)

## ២.១. លក្ខណៈរូបរាង

ត្រីអណ្តែងកូនកាត់ មានដងខ្លួនវែង រាងមូលពីផ្នែកកណ្តាល សំប៉ែតនៅផ្នែកកន្ទុយ រលោង និងមានទឹករំអិលច្រើន។ ក្បាលត្រីមានរាងសំប៉ែង រឹង មានពុកមាត់៤គូ សម្រាប់រាវរកចំណី។ ជាទូទៅខ្លួនត្រីមានសម្បុរពណ៌ខ្មៅប្រផេះឬត្នោតចាស់ និងមានអុជតូចៗលើដងខ្លួនកាត់តាមត្រីអណ្តែងរឹង។ ផ្នែកពោះមានពណ៌សឬលឿងខ្ចី ចំណែកព្រុយខ្នង និងព្រុយពោះវែងរហូតដល់កន្ទុយ និងដាច់ដោយឡែកពីគ្នា មិនជាប់គ្នាដូចត្រីអណ្តែងទន្លេ។

**ការកំណត់សម្គាល់រូបរាងត្រីអណ្តែង ៤ប្រភេទ÷**

១. ត្រីអណ្តែងរឹង (Clarias batrachus)

២. ត្រីអណ្តែងទន់ (Clarias macrocephalus)

៣. ត្រីអណ្តែងកូនកាត់ (Hybrid Catfish / Hybrid walking catfish)

៤. ត្រីអណ្តែងអាហ្វ្រិច (Clarias gariepinus)




ត្រីអណ្តែងរឹង ***Clarias Batrachus***



ត្រីអណ្តែងទន់ ***Clarias Macrocephalus***



ត្រីអណ្តែងកូនកាត់ ***Hybrid Walking Catfish***



ត្រីអណ្តែងអាហ្វ្រិច ***Clarias Gariepinus***

ប្រភព ÷ *វេទ្ឌបាលជលផល- បច្ចេកទេសស្តីពីការផលិតពូជ និងការចិញ្ចឹមត្រីអណ្តែងអាហ្វ្រិច និងត្រីអណ្តែងកាត់ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។*

## ២.២. មជ្ឈដ្ឋានរស់នៅ

ត្រីអណ្ដែងអាចរស់នៅបានទាំងក្នុងស្រះ បឹង ទន្លេ ស្ទឹង អាចបន្សាំខ្លួនបានយ៉ាងទូលំទូលាយជាមួយមជ្ឈដ្ឋានទឹកសាប។ ត្រីអណ្ដែងកូនកាត់មានសរីរាង្គដកដង្ហើមបន្ទាប់បន្សំម្យ៉ាងហៅថា "Arborescent organ" ដែលស្ថិតនៅផ្នែកខាងលើនៃស្រកី។ សរីរាង្គនេះអនុញ្ញាតឱ្យត្រីអាចស្រូបយកអុកស៊ីសែនផ្ទាល់ពីបរិយាកាស ធ្វើឱ្យត្រីអាចរស់នៅក្នុងទឹកដែលមានកម្រិតអុកស៊ីសែនទាប ឬនៅលើគោកបានមួយរយៈពេល (ដរាបណាស្បែកវានៅមានសំណើម)។ គុណភាពទឹកគឺជាកត្តាសំខាន់បំផុតដែលកំណត់ពីល្បឿនលូតលាស់ និងអត្រារស់របស់ត្រីអណ្ដែងកាត់។ ទោះបីជាប្រភេទត្រីដែលមានភាពធន់ខ្លាំងក៏ដោយ ប៉ុន្តែដើម្បីទទួលបានទិន្នផលខ្ពស់ កសិករគួរគ្រប់គ្រងគុណភាពទឹកឱ្យបានសមស្របមានដូចខាងក្រោម÷

| លរ | សន្ទស្សន៍គុណភាពទឹក | កម្រិតល្អបំផុត | កម្រិតអាចទ្រាំទ្របាន |
|---|---|---|---|
| 1 | សីតុណ្ហភាព (ºC) | 28 - 30 | 11 - 39.5 |
| 2 | កម្រិត pH | 7.0-8.0 | 3.5 - 10.5 |
| 3 | អុកស៊ីសែន (mg/L) | > 3.0 | > 0.5 |
| 4 | កម្រិតប្រៃនៃទឹក (ppt) | 0 - 5 | < 15 |
| 5 | អាម៉ូញាក់-$NH_3$ (mg/L) | 0 – 0.02 | < 0.1 |
| 6 | នីទ្រីត-Nitrite (mg/L) | < 0.1 | < 0.5 |
| 7 | នីត្រាត-Nitrate (mg/L) | 0 - 50 | < 100 |

***កំណត់ចំណាំ÷***

- **សីតុណ្ហភាព÷** ប្រសិនជាសីតុណ្ហភាពក្ដៅលើសពី ៣៥ºC ត្រីងាយនឹងស្ត្រេស និងកើតជំងឺ។ ប្រសិនជាត្រជាក់ខ្លាំងក្រោម ១៥ºC ត្រីនឹងផ្អាកស៊ីចំណី និងលូតលាស់យឺត។
- **pH÷** ប្រសិនបើទឹកមានអាស៊ីតខ្លាំង (pH ទាប) ត្រីនឹងបញ្ចេញរំអិលច្រើន ពិបាកដកដង្ហើម។ កសិករអាចប្រើ កំបោរស (CaO) ដើម្បីកែតម្រូវកម្រិត pH ក្នុងស្រះ។
- **អុកស៊ីសែន (DO)÷** ត្រីអាចរស់នៅក្នុងទឹកដែលមានអុកស៊ីសែនទាបរហូតដល់ 0.5mg/L បាន ប៉ុន្តែវានឹងបង្កឱ្យត្រីហត់ និងមិនសូវស៊ីចំណី។
- **កម្រិតប្រៃនៃទឹក÷** ប្រសិនបើភាពប្រៃលើសពី ១៥ ppt ត្រីចាប់ផ្ដើមបាត់បង់ជាតិទឹកពីក្នុងខ្លួន ស្បែកប្រែជាស្លេក ពិបាកដកដង្ហើម ស៊ីចំណីតិច និងអាចងាប់ក្នុងរយៈពេលយូរ។
- **អាម៉ូញាក់ ($NH_3$)÷** កើតចេញពីកាកសំណល់ចំណីដែលនៅសល់ និងលាមកត្រី។ ប្រសិនបើអាម៉ូញាក់ខ្ពស់លើសពី ០.២ mg/L ទឹកនឹងមានក្លិនស្អុយ ធ្វើឱ្យត្រីពុល ហើមស្រកី ពិបាកដកដង្ហើម និងងាប់ជាបន្តបន្ទាប់។

- **នីទ្រីត ($NO_2$)** ÷ លើសពី 0.5 mg/L អាចធ្វើឱ្យត្រីកើតជំងឺ “**ឈាមត្នោត**” (Brown Blood Disease) ដែលត្រីហត់ខ្លាំងទោះបីក្នុងទឹកមានអុកស៊ីសែនច្រើនក៏ដោយ។
- **នីត្រាត ($NO_3$)** ÷ ប្រសិនបើនីត្រាតឡើងខ្ពស់ពេក ធ្វើឱ្យស្លែដុះច្រើន (ទឹកខៀវក្រម៉ៅ) ដែលអាចធ្វើឱ្យបាត់បង់អុកស៊ីសែននៅពេលយប់។





## ២.៣. ចរិតស៊ីចំណី

នៅក្នុងប្រភពទឹកធម្មជាតិ ត្រីអណ្តែងកូនកាត់មានទំនោរទៅរកការស៊ីសាច់ច្រើនជាងការស៊ីប្រភេទរុក្ខជាតិ។ ត្រីស៊ីប្រភេទសត្វល្អិតក្នុងទឹក កូនត្រីតូចៗ កង្កែប ខ្ចៅ ខ្យង កំពឹស និងពពួកសត្វប្លង់តុង។ នៅពេលខ្សត់ចំណីប្រភេទសាច់ ត្រីក៏ស៊ីប្រភេទរុក្ខជាតិទឹក និងកាកសំណល់សរីរាង្គផងដែរ។ ត្រីអណ្តែង ជាសត្វរកស៊ីចំណីពេលយប់ ដោយប្រើពុកមាត់ ដើម្បីរាវរកចំណីក្នុងល្បាប់ភក់ ឬទឹកល្អក់។

ក្នុងការចិញ្ចឹម ត្រីអណ្តែងកូនកាត់ត្រូវបានបង្វឹកឱ្យស៊ីចំណីបានយ៉ាងងាយស្រួល និងលូតលាស់លឿន ដោយអាចផ្តល់ជាចំណីគ្រាប់ និងចំណីផ្សំ។ ចំណីគ្រាប់អណ្តែតទឹក និងមានប្រូតេអ៊ីនចន្លោះពី ២៥-៣២% សម្រាប់ការចិញ្ចឹមយកសាច់ ចំណែកចំណីផ្សំ មានដូចជា ប្រភេទកាកសំណល់ផ្ទះបាយ ពោះវៀនសត្វ កន្ទក់ ចុងអង្ករ ម្សៅត្រី ឬកូនត្រីល្អិតជាដើម។ ត្រីអណ្តែងកូនកាត់មានចរឹកដណ្តើមគ្នា ស៊ីចំណីខ្លាំង ដែលធ្វើឱ្យមានភាពងាយស្រួលក្នុងការដាក់ចំណី។





**២.៤.ការលូតលាស់÷**

ត្រីអណ្ដែងកូនកាត់ ត្រូវបានចាត់ទុកជាប្រភេទពូជរាតត្បាត ដោយសារសមត្ថភាពរស់រាន និងការលូតលាស់ដ៏ខ្លាំងក្លា។ ក្នុងធម្មជាតិទោះបីជាគ្មានការផ្ដល់ចំណីដូចក្នុងស្រះចិញ្ចឹម ក៏ត្រីអណ្ដែងកាត់នៅតែលូតលាស់លឿន។ ត្រីអាចលូតលាស់រហូតដល់ទម្ងន់ពី ២-៣គីឡូក្រាម/ក្បាល ប្រសិនបើត្រីអាចរស់រានលើសពី១ឆ្នាំ ដែលទំហំនេះធំជាងត្រីអណ្ដែងទន់ធម្មជាតិ ២-៣ដង។ សម្រាប់ការចិញ្ចឹមដែលផ្ដល់ចំណីគ្រប់គ្រាន់ ក្នុងរយៈពេលពី ៣-៤ខែ ត្រីអាចឡើងទម្ងន់ពី ២០០-៥០០ក្រាម/ក្បាល (អាស្រ័យលើដង់ស៊ីតេ និងគុណភាពចំណី)។ ដំណាក់កាលលូតលាស់លឿនបំផុតគឺនៅចន្លោះខែទី២ ដល់ខែទី៣ បន្ទាប់ពីការដាក់កូនត្រីពូជចិញ្ចឹម។ ត្រីអណ្ដែងកូនកាត់មានលក្ខណៈលូតលាស់បែបអាយសូម៉ែត្រ (Isometric Growth) គឺការកើនឡើងទម្ងន់សមាមាត្រនឹងការកើនឡើងប្រវែង ដែលជាលក្ខណៈល្អសម្រាប់ត្រីសាច់ក្នុងពាណិជ្ជកម្ម។

**២.៥.ការបន្តពូជ÷**




ការបន្តពូជត្រីអណ្ដែងកាត់ត្រូវបានអនុវត្តតាម **វិធីសាស្ត្របង្កាត់សិប្បនិម្មិត** ដោយប្រើប្រាស់អ័រម៉ូនជំរុញ ការធ្វើបែបនេះគឺដោយសារក្នុងលក្ខខណ្ឌចិញ្ចឹមធម្មតា ត្រីប្រភេទនេះកម្រនឹងបន្តពូជដោយខ្លួនឯងណាស់ ប្រសិនបើគ្មានសារធាតុរំញោច ឬការរៀបចំបរិស្ថានសមស្រប។

- **ត្រីពេញវ័យ÷** ត្រីអណ្ដែងកាត់ឆាប់ឈានដល់វ័យបន្តពូជ ជាទូទៅចាប់ពីអាយុ ៨ ខែឡើងទៅ។
- **រដូវបន្តពូជ÷** ចាប់ផ្ដើមពីខែមេសា ដល់ខែតុលា ប៉ុន្តែសកម្មភាពបន្តពូជឈានដល់កម្រិតខ្ពស់បំផុតនៅក្នុងរដូវវស្សា គឺចន្លោះពី **ខែឧសភា ដល់ខែកក្កដា** (អាចអូសបន្លាយដល់ខែសីហា)។
- **វដ្តបន្តពូជ÷** ក្នុងមួយឆ្នាំ ត្រីអណ្ដែងកាត់អាចបង្កាត់បានពី ៤-៦ដង។ ប្រសិនបើការចិញ្ចឹម និងថែទាំមេបាបានល្អតាមបច្ចេកទេស វដ្តនេះអាចកើនឡើងរហូតដល់ ៨-១១ដងក្នុងមួយឆ្នាំ។ បន្ទាប់ពីការបង្កាត់លើកទីមួយ ត្រីញីអាចបង្កាត់ពូជឡើងវិញបានក្នុងរយៈពេលត្រឹមតែ **១៥ - ២០ ថ្ងៃ** (ឬយូរបំផុត ៣០ថ្ងៃ) ប្រសិនបើត្រីទទួលបានរបបចំណី និងការថែទាំត្រឹមត្រូវ។
- **លក្ខណៈពង÷** ពងត្រីអណ្ដែងកាត់មានលក្ខណៈ ស្អិត។

- **ការភ្ញាស់÷** ដោយសារពងមានជាតិស្អិត គេត្រូវភ្ញាស់វានៅក្នុងអាងដែលមានបំពាក់សម្ភារៈសម្រាប់ឱ្យពងត្រីតោងជាប់ (ដូចជា សំណាញ់ ឬស្បៃមុង) ដើម្បីធានាអត្រាញាស់ខ្ពស់។



## ៣-បច្ចេកទេសបង្កាត់ភ្ញាស់ត្រីអណ្តែងកូនកាត់

### ៣.១. ការចិញ្ចឹមបំប៉នត្រីមេបា

- **ស្រះចិញ្ចឹមបំប៉ន÷** ផ្ទៃក្រឡាតូចចាប់ពី១០ម៉ែត្រការ៉េ រហូតដល់រាប់រយម៉ែត្រការ៉េ សំខាន់ត្រូវមាំទាំ មិនមានការលេចជ្រាបទឹក អាចរក្សាកម្រិតទឹកចន្លោះពី ១.២-១.៥ម៉ែត្រ។ ជារួមស្រះចិញ្ចឹមបំប៉នត្រីមេបា ត្រូវរៀបចំឱ្យមានលក្ខណៈដូចស្រះចិញ្ចឹមត្រីសាច់ផងដែរ។
- **ដង់ស៊ីតេត្រី÷** ដង់ស៊ីតេដាក់ត្រីមេបាគឺចន្លោះពី ០.៥ ដល់ ០.៨ គីឡូក្រាម ក្នុងមួយម៉ែត្រការ៉េ ដោយប្រើសមាមាត្រ ត្រីឈ្មោល និងត្រីញី គឺ ២ : ១ ឬ ៣ : ១។
- **របបចំណី÷**
  - **កម្រិតចំណី÷** ផ្តល់ ២ដង/ថ្ងៃ ក្នុងបរិមាណ ១.៥% ទៅ ៣% នៃទម្ងន់មេបាសរុប។
  - **គុណភាព÷** ចំណីត្រូវមានកម្រិតប្រូតេអ៊ីនពី ៣០% ទៅ ៣៥%។
  - **ចំណីផ្សំ÷** ម្សៅត្រី(៣០-៤០%), កន្ទក់(៤០%), និងម្សៅសណ្តែកសៀង(២០-៣០%)។ អាចបន្ថែមចំណីស្រស់ (ត្រីចម្រុះ ឬកាកសំណល់សត្តឃាត) ១ដងក្នុងមួយសប្តាហ៍។
- **ការថែទាំ÷** មុនពេលបង្កាត់ ២-៤សប្តាហ៍ ត្រូវបន្ថយបរិមាណចំណី ប៉ុន្តែរក្សាកម្រិតប្រូតេអ៊ីន និងវីតាមីនឱ្យខ្ពស់ ដើម្បីបង្ការកុំឱ្យត្រីធាត់ខ្លាញ់ពេក។
- **ផលប៉ះពាល់នៃការធាត់ខ្លាញ់÷** ត្រីមេពូជល្អមានពោះធំហើយទន់។ បើពោះរឹង ហើយមូលខ្លីបញ្ជាក់ថាត្រីធាត់ខ្លាញ់ខ្លាំង។ ខ្លាញ់ដែលលើសនឹងទៅសង្កត់បំពង់នាំពង/មេជីវិត ធ្វើឱ្យពិបាករីត និងរារាំងការបង្កកំណើតក្នុងកោសិកាពង។ ត្រីធាត់ខ្លាំងមានប្រតិកម្មយឺតជាមួយអ័រម៉ូន បណ្តាលឱ្យបញ្ចេញពងមិនអស់ មិនស្មើគ្នា ឬមិនបានល្អ។





### ៣.២. ការជ្រើសរើសត្រីមេបា

ត្រីមេបាត្រូវមានអាយុចាប់ពី ៨-១២ខែឡើងទៅ និងមានទម្ងន់ចន្លោះពី ០.៨-១.៥ គីឡូក្រាម ក្នុងមួយក្បាល។ ត្រីអណ្តែងញីពេញវ័យ គឺមានពោះធំ ទន់ល្មើយស្មើល្អ រន្ធបន្តពូជមានរាងជាកង រង្វង់ ប៉ោងធំ និងមានពណ៌ក្រហមខ្ចី។ ពេលអង្អែល ឬច្របាច់ពោះត្រីស្រាលៗពីលើចុះក្រោមនឹង ឃើញមានពងហូរចេញមក មានទំហំប៉ុនៗគ្នា តឹងមូល និងមានពណ៌សម្គាល់ជាក់លាក់។ ចំណែក ត្រីឈ្មោល ប្រដាប់បន្តពូជវែង រាងត្រីកោណ មានចុងស្រួចតូច លយចេញមកខាងក្រោយ មាន ពណ៌ស ឬលឿងខ្ចី ប៉ុន្តែនៅរដូវបង្កាត់ពូជ មានពណ៌ផ្កាឈូកខ្ចី។










### ៣.៣. ការបង្កាត់បែបសប្បនិម្មិត

ការបង្កាត់បែបសិប្បនិម្មិត គឺជាបច្ចេកទេសដ៏មានប្រសិទ្ធភាពបំផុតសម្រាប់ត្រីអណ្តែងកាត់ ព្រោះអនុញ្ញាតឱ្យកសិករអាចគ្រប់គ្រងបរិមាណពង និងមេជីវិតបានច្បាស់លាស់។ ត្រីអណ្តែងឈ្មោលមិនអាចរីតយកទឹកមេជីវិតដូចត្រីឆ្តោ ឬត្រីប្រាបាន កសិករត្រូវអនុវត្តដូចខាងក្រោម÷

#### ៣.៣.១. ការចាក់ថ្នាំអ័រម៉ូន

ការចាក់អ័រម៉ូន ដើម្បីជួយជំរុញឱ្យពងត្រីញីឆាប់ទុំ និងត្រីឈ្មោលមានទឹកមេជីវិតច្រើន។ ប្រភេទអ័រម៉ូន ដែលនិយមយកមកប្រើប្រាស់មានដូចជា÷ ហាស់សេហ្សេ (HCG) ស៊ូព្រីហ្វាក (Suprefact) ស៊ីនណាហ្វាក (Cinnafact) និងអូវ៉ាព្រីម (Ovaprim) ។ ដោយឡែក នៅក្នុងឯកសារបច្ចេកទេសនេះ នឹងលើកយកអ័រម៉ូនតែមួយប្រភេទប៉ុណ្ណោះ ដើម្បីមកពន្យល់បកស្រាយបង្ហាញជូនអំពីតួនាទី របៀបប្រើប្រាស់ និងប្រសិទ្ធភាពក្នុងការបង្កាត់ត្រីអណ្តែងដូចខាងក្រោម÷

❖ **<u>ប្រភេទ និងតួនាទីថ្នាំអ័រម៉ូន÷</u>**

- **ស៊ីនណាហ្វាក (Cinnafact)÷** ជាអ័រម៉ូនជំរុញជួយឱ្យត្រីមេបញ្ចេញពងបានល្អ
- **ដុំភើរីដុន (Domperidone)÷** ជាថ្នាំជំនួយ ដើម្បីឱ្យអ័រម៉ូនមេធ្វើការបានពេញលេញ ពងត្រីទុំស្មើល្អ និងធ្លាក់មកបានយ៉ាងមានប្រសិទ្ធភាព។
- **សារ៉ូមប្រៃ (NaCl 0.9%)÷** ដោយសារ Domperidone ជាថ្នាំគ្រាប់ មិនអាចរលាយក្នុងទឹកធម្មតាបានល្អឡើយ ហេតុនេះត្រូវប្រើ សារ៉ូមប្រៃ ដើម្បីរំលាយថ្នាំឱ្យមានលក្ខណៈជាល្បាយទឹកអាចចាក់ចូលសាច់ដុំត្រីបាន។

**ថ្នាំអ័រម៉ូន សម្រាប់បង្កាត់ត្រីអណ្តែង**



Cinnafact



Domperidone



សារ៉ូមប្រៃ 0.9%

❖ **របៀបលាយផ្សំថ្នាំ÷**

រូបមន្តផ្សំថ្នាំសម្រាប់ត្រីមេពូជទម្ងន់ ១០គីឡូក្រាម កសិករអាចរៀបចំដូចខាងក្រោម÷

- **ដុំភើរីដូន (Domperidone)÷** យកថ្នាំចំនួន ៥គ្រាប់ មកបុកឱ្យម៉ត់ល្អ កុំឱ្យមានដុំតូចៗ ដែលធ្វើឱ្យស្ទះម្ជុល។
- **ការរំលាយ÷** ចាក់សារ៉ូមប្រៃ ៤.៥មីលីលីត្រ ចូលទៅក្នុងម្សៅថ្នាំ Domperidone រួចកូរឱ្យរលាយសព្វល្អ។
- **ការបន្ថែម Cinnafact÷** បូមយកអ័រម៉ូន Cinnafact ចំនួន ០.៥មីលីលីត្រ លាយបញ្ចូលគ្នាជាមួយល្បាយទឹកថ្នាំ Domperidone ដែលរំលាយរួច។
- **លទ្ធផល÷** ទទួលបានល្បាយទឹកថ្នាំអ័រម៉ូនសរុបប្រហែល ៥មីលីលីត្រ សម្រាប់ចាក់លើត្រីមេពូជចំនួន ១០គីឡូក្រាម។






❖ **កម្រិតប្រើប្រាស់ថ្នាំ÷** ការប្រើប្រាស់ត្រូវបែងចែកតាមប្រភេទត្រី រួមមាន÷

| ប្រភេទត្រី | កម្រិតថ្នាំត្រូវចាក់ | រយៈពេលរង់ចាំ |
|---|---|---|
| ត្រីញី | ០.៥មីលីលីត្រ ក្នុងទម្ងន់ត្រី១គីឡូក្រាម | ៨ ទៅ ១២ម៉ោង |
| ត្រីឈ្មោល | ០.២ - ០៣មីលីលីត្រ ក្នុងទម្ងន់ត្រី១គីឡូក្រាម | ចាក់ដំណាលគ្នាត្រីញី ឬក្រោយពេល ២ម៉ោង |

❖ **របៀបចាក់ថ្នាំ÷** ប្រើម្ជុលចាក់បញ្ចូលទៅក្នុងសាច់ដុំខ្នង នៅចន្លោះព្រុយខ្នង និងខ្សែឆ្នូតចំហៀង។ ចាក់ម្ជុល ក្នុងមុំ ៤៥ ដឺក្រេ និងជម្រៅប្រហែល ១-១.៥សង់ទីម៉ែត្រ (អាស្រ័យលើទំហំត្រី) ជៀសវាងការប៉ះទង្គិចដល់ឆ្អឹងខ្នង ឬសរីរាង្គក្នុង។ ក្រោយពេលចាក់ប្រើម្រាមដៃញីកន្លែងចាក់ស្រាលៗ ដើម្បីឱ្យថ្នាំជ្រាបចូលសាច់ដុំបានល្អ និងការពារកុំឱ្យថ្នាំហូរចេញ។




### ៣.៣.២.ការវះយកក្រពេញមេជីវិតឈ្មោល

ត្រូវបង្អត់ចំណីត្រីយ៉ាងតិច ១២ម៉ោង មុនពេលវះកាត់ ដើម្បីឱ្យពោះវៀនស្អាត ងាយស្រួលរកក្រពេញមេជីវិត និងកាត់បន្ថយការចម្លងរោគពីលាមក។ ជំហាននៃការវះកាត់រួមមាន÷

- **ការសម្លាប់ត្រី÷** ត្រូវសម្លាប់ត្រីដោយវាយក្បាល និងកាត់ឆ្អឹងខ្នងត្រង់ក។
- **ការវះពោះត្រី÷** ប្រើកាំបិតមុតស្រួច ឬកន្ត្រៃវះតាមបណ្តោយពោះ ចាប់ពីក្រោមព្រុយទ្រូង រហូតដល់រន្ធបន្តពូជ។
- **ការរកក្រពេញមេជីវិត÷** មានទីតាំងនៅជាប់នឹងឆ្អឹងខ្នង និងនៅពីក្រោយថង់ខ្យល់ មានរាងជាសរសៃវែងៗពីរឆ្វេងស្តាំ មានពណ៌សថ្លា ឬសដូចទឹកដោះគោ។
- **ការកាត់យក÷** ប្រើដង្កៀបចាប់ និងកន្ត្រៃកាត់យកមេជីវិត ដោយមិនត្រូវឱ្យបែកថង់ប្រមាត់ ឬពោះវៀននោះទេ។
- **ការលាងសម្អាត÷** លាងក្រពេញមេជីវិតក្នុងទឹកសេរ៉ូមប្រៃ (០.៩%) ឱ្យបានស្អាត។
- **ការរក្សាទុក÷** មេជីវិតអាចរក្សាទុកក្នុងទឹកសេរ៉ូម រួចដាក់ក្នុងទូទឹកកកក្នុងសីតុណ្ហភាព ៤អង្សា និងអាចរក្សាទុកបានរហូតដល់ ២៤-៤៨ម៉ោង។







### ៣.៣.៣. ការច្បូតយកពង

ក្រោយពេលចាក់អ័រម៉ូនរួច ៨-១២ ម៉ោង (អាស្រ័យលើសីតុណ្ហភាពទឹក ២៨°C-៣០°C) ត្រូវពិនិត្យមេត្រី។ ចាប់ត្រីផ្ងារពោះ រួចប្រើម្រាមដៃច្បូតស្រាលៗលើពោះទៅរន្ធប្រដាប់ភេទ ប្រសិនបើពោះទន់ខ្លាំង ហើយពងត្រីហូរចេញមកងាយស្រួល មានពណ៌លឿងថ្លាឬត្នោតខ្ចី មិនស្អិតជាប់គ្នា នោះមានន័យថាដល់ពេលច្បូតយកពងមកបង្កាត់ហើយ។ ប៉ុន្តែ បើច្របាច់ទៅឃើញមានលាយឈាម ឬពងនៅស្អិតជាប់គ្នាខ្លាំង ត្រូវរងចាំ ១-២ម៉ោងទៀត ឬមេត្រីមិនអាចយកមកបង្កាត់បានទៀតទេ។

❖ **ឧបករណ៍ត្រូវត្រៀម÷**

- ចានជ័រ ឬដែក (ត្រូវតែស្ងួតស្អាត ១០០%)
- កន្សែងស្ងួត និងទន់
- រោមមាន់ ឬស្លាបមាន់ (សម្រាប់កូរបង្កាត់)
- សារ៉ូមប្រៃ (NaCl 0.9%) និងទឹកស្អាត

❖ **ជំហាននៃការច្បូតយកពង÷**

- **ធ្វើឱ្យត្រីស្ងួត÷** ជាចំណុចសំខាន់បំផុត។ ប្រើកន្សែងជូតខ្លួនត្រី ពិសេសត្រង់កន្ទុយ និងរន្ធបន្តពូជឱ្យស្ងួតល្អ។ ហាមដាច់ខាត កុំឱ្យទឹកហូរចូលក្នុងចានដាក់ពង ព្រោះទឹកនឹងធ្វើឱ្យរន្ធពងបិទជិតភ្លាមៗ ធ្វើឱ្យមេជីវិតឈ្មោលមិនអាចចូលបង្កកំណើតបាន។
- **របៀបកាន់ត្រី÷** ប្រើកន្សែងរុំក្បាលត្រីឱ្យណែន (ដើម្បីកុំឱ្យរើ ឬរអិល) រួចកាន់ត្រីផ្តេកពោះចុះបន្តិចឱ្យចំពីលើចានដែលត្រៀមទុក។
- **ការច្របាច់÷** ប្រើមេដៃ និងម្រាមចង្អុល សង្កត់ស្រាលៗចាប់ពីផ្នែកខាងក្រោមព្រុយត្រចៀក រួចអូសយឺតៗឆ្ពោះទៅកាន់រន្ធបន្តពូជ។ អនុវត្តបែបនេះ ២-៣ដង រហូតដល់អស់ពង (ពោះត្រីចាប់ផ្តើមស្វិត)។





## ៣.៣.៤.ការបង្កាត់÷

យកក្រពេញមេជីវិតឈ្មោល ដែលបានវះកាត់រួចរាល់មកកាត់ឱ្យល្អិត និងប្រើទឹកសេរ៉ូមពង្រាវមេជីវិតឈ្មោល ដើម្បីងាយស្រួលយកមកបង្កកំណើតជាមួយពង។ ដំណើរការបង្កកំណើតមានដូចខាងក្រោម÷

- **ការបង្កកំណើត÷** ចាក់មេជីវិតឈ្មោលដែលបានលាយរួច ចូលទៅក្នុងចានពងត្រីភ្លាមៗ។
- **ការកូរ÷** ប្រើរោមមាន់កូរឱ្យសព្វរយៈពេលប្រហែល ១ នាទី។ ក្នុងដំណាក់កាលនេះ ពង និងមេជីវិតឈ្មោល ស្ថិតក្នុងស្ថានភាពខាប់ ដែលមានសារ៉ូមប្រែបន្តិចបន្តួច។
- **ការបន្ថែមទឹក÷** ចាក់ទឹកស្អាតចូលបន្តិច រួចបន្តកូរឱ្យសព្វ។ ទឹកនឹងធ្វើឱ្យមេជីវិតឈ្មោលចាប់ផ្តើមហែលយ៉ាងលឿនចូលទៅក្នុងពង ដើម្បីបង្កកំណើតក្នុងរយៈពេលត្រឹមតែ ៣០ វិនាទី ទៅ២នាទីប៉ុណ្ណោះ មុនពេលមេជីវិតអស់កម្លាំង និងងាប់ទៅវិញ។
- **ការលាងសម្អាតពង÷** បន្ទាប់ពីកូរជាមួយទឹកបាន ១-២ នាទី ត្រូវលាងពងត្រីជាមួយទឹកស្អាត ២-៣ ដង ដើម្បីជម្រះកម្ទេចកម្ទីក្រពេញទឹកកាម និងជាតិរំអិលចេញ កុំឱ្យពងត្រីស្អិតជាប់គ្នាខ្លាំងពេក ធ្វើឱ្យខូះអុកស៊ីសែន រាំងស្ទះដល់ការបង្កកំណើត។
- **ការពិនិត្យពង÷** ពងត្រីដែលបង្កកំណើតជោគជ័យនឹងប្រែទៅជាពណ៌**លឿងថ្លា** ចំណែកពងដែលមិនបង្កកំណើត នឹងប្រែទៅជាពណ៌**សល្អក់**។

***<u>កំណត់ចំណាំ</u>÷ ក្នុងអំឡុងពេលច្បូតពង និងបង្កាត់ គួរធ្វើនៅក្នុងម្លប់ ឬកន្លែងដែលមិនមានពន្លឺថ្ងៃខ្លាំង ដើម្បីរក្សាគុណភាពមេជីវិត និងពងត្រីឱ្យនៅល្អបំផុត។***



### ៣.៣.៥.ការភ្ញាស់៖

បន្ទាប់ពីដំណើរការបង្កកំណើតបានសម្រេច ដំណាក់កាលបន្ទាប់គឺការថែទាំ និងការភ្ញាស់ពងឱ្យចេញជាកូនត្រី។ ចំណុចសំខាន់ៗនៃការភ្ញាស់រួមមានដូចខាងក្រោម៖

- យកពងត្រីដែលបានបង្កកំណើតរួច ទៅរាយស្តើង និងសព្វល្អនៅលើស៊ុមស្បៃ រួចយកទៅដាក់ក្នុងអាងភ្ញាស់ដែលមានប្រព័ន្ធទឹកហូរ និងអុកស៊ីសែនគ្រប់គ្រាន់។ មិនត្រូវឱ្យពងត្រួតលើគ្នាជាដុំទេ ពីព្រោះពងដែលនៅខាងក្រោមនឹងខ្វះអុកស៊ីនសែន បង្កជាមេរោគផ្សិត។
- ស៊ុមស្បៃគួរដាក់នៅក្រោមផ្ទៃទឹកប្រហែល ៥ - ១០សង់ទីម៉ែត្រ
- ត្រូវមានម៉ាស៊ីនបាញ់ខ្យល់ ឬប្រព័ន្ធទឹកហូរតិចៗ ដើម្បីផ្តល់អុកស៊ីសែនដល់ពង។
- សីតុណ្ហភាពទឹកសមស្របចន្លោះពី **២៨ - ៣០អង្សាសេ** ប្រសិនជាសីតុណ្ហភាពទឹកត្រជាក់ពេក ពងត្រីនឹងញាស់យឺត ឬអាចរលួយ។ ប្រសិនជាសីតុណ្ហភាពខ្ពស់ពេក នាំឱ្យកូនត្រីដែលកើតចេញមកខូចទ្រង់ទ្រាយ សរីរាង្គមិនពេញលក្ខណៈ ឬងាប់ក្នុងសំបកពងមុនពេលញាស់ចេញមកក្រៅ។
- រយៈពេលពី **១៨ - ២៤ម៉ោង** (សីតុណ្ហភាពសមស្រប) កូនត្រីអណ្តែងចាប់ផ្តើមញាស់






- **ការគណនាអត្រាញាស់៖** អត្រាញាស់ គឺជាជំហានសំខាន់មួយក្នុងការវាយតម្លៃពីប្រសិទ្ធភាពនៃការបង្កាត់ និងគុណភាពមេពូជ។ ដើម្បីគណនាអត្រាញាស់ ត្រូវដឹងពីសមាសភាពពីរគឺ ចំនួនកូនត្រីដែលបានញាស់ និងចំនួនពងត្រីសរុបដែលបានដាក់ភ្ញាស់។

រូបមន្តគណនាអត្រាញាស់៖

$$\textbf{អត្រាញាស់ (\%)} = \frac{\text{ចំនួនកូនត្រីដែលញាស់សរុប}}{\text{ចំនួនពងត្រីសរុបដែលបានដាក់ភ្ញាស់}} \times 100$$

ដោយសារពងត្រីអណ្តែងមានចំនួនច្រើន (រាប់ម៉ឺនគ្រាប់) កសិករមិនអាចរាប់ម្តងមួយគ្រាប់បានទេ ដូច្នេះត្រូវប្រើវិធីសាស្ត្រប៉ាន់ស្មានតាមរយៈការធ្វើសំណាកគំរូ៖

- **ការប៉ាន់ស្មានចំនួនពងត្រីដែលបានដាក់ភ្ញាស់៖** ដោយថ្លឹងទម្ងន់ពងសរុប រួចយកសំណាក់ពងត្រី ១ក្រាម មករាប់ចំនួនគ្រាប់។ បន្ទាប់មកគុណនឹងទម្ងន់ពងត្រីសរុប។ *<u>ឧទាហរណ៍</u>៖* បើពងត្រីទម្ងន់ ១ក្រាម មាន ៧០០គ្រាប់ បើមានពងសរុប ៥០០ ក្រាម នោះពងត្រីសរុបគឺ ៧០០ គុណនឹង ៥០០ ស្មើនឹង **៣៥០,០០០ គ្រាប់។**
- **ការប៉ាន់ស្មានចំនួនកូនត្រីដែលញាស់៖** យកកែវគំរូមួយដងកូនត្រីអាយុប្រហែល ២-៣ថ្ងៃ រាប់ចំនួនកែវសរុប។ បន្ទាប់មកយកសំណាកកូនត្រី ១កែវ មករាប់ចំនួនកូនត្រីសរុបក្នុង១កែវ។ បន្ទាប់មក យកចំនួនកូនត្រីក្នុង១កែវ គុណនឹងចំនួនកែវសរុប ។ *<u>ឧទាហរណ៍</u>៖* បើកូនត្រីសរុបមានចំនួន ៤០០ កែវ និងក្នុង១កែវ មានកូនត្រីចំនួន ៧០០ក្បាល។ ដូចនេះ ចំនួនកូនត្រីដែលបានញាស់សរុបគឺ ៤០០ កែវ គុណនឹង ៧០០ ក្បាល ស្មើនឹង **២៨០,០០០ ក្បាល។**

$$\textbf{អត្រាញាស់ (\%)} = \frac{២៨០,០០០}{៣៥០,០០០} \times ១០០ = \boxed{៨០\ \%}$$

អត្រាញាស់ ៨០% ខាងលើនេះ កសិករអាចដឹងអំពីផលិតភាពសរុប គឺផ្តោតលើភាពជោគជ័យជារួម តាំងពីការជ្រើសរើសមេពូជ បច្ចេកទេសបង្កាត់ បរិស្ថានទឹកក្នុងអាងបង្កាត់ ការគ្រប់គ្រង និងការចំណាយពងត្រីអស់ប៉ុន្មាន ទទួលបានកូនត្រីមកវិញប៉ុន្មាន។

  

### ៣.៣.៦. ការថែទាំដំបូង÷

បន្ទាប់ពីបង្កាត់បាន ២៤ម៉ោង នៅក្នុងអាងភ្ញាស់សម្បុរទៅដោយកូនត្រី លាយឡំជាមួយនិងកម្ទេចកម្ទីសំបកពង កសិករត្រូវធ្វើការថែទាំដូចខាងក្រោម÷

- ដកស៊ុមស្បៃសំណាញ់ចេញ ដួសឬបូមយកសំបកពងដែលស្អុយ និងពងដែលមិនញាស់ចេញពីអាង ដើម្បីការពារកុំឱ្យខូចទឹក។
- រក្សាកម្រិតទឹកក្នុងអាងភ្ញាស់ចន្លោះពី **១៥- ២៥សង់ទីម៉ែត្រ** ដើម្បីឱ្យកូនត្រីងាយស្រួលហែលឡើងមកដកដង្ហើមនៅផ្ទៃខាងលើ។
- បន្តផ្តល់អុកស៊ីសែនកម្រិតស្រាល ឬចរន្តទឹកតិចៗ ដើម្បីឱ្យកូនត្រីមានកម្លាំងលូតលាស់
- រក្សាសីតុណ្ហភាពឱ្យស្ថិតក្នុងចន្លោះ **២៨- ៣០អង្សាសេ** ប
- មិនត្រូវផ្តល់ចំណីក្នុងរយៈពេល **៤៨ម៉ោង** ដំបូង ពីព្រោះកូនត្រីមិនទាន់មានមាត់ និងប្រព័ន្ធរំលាយអាហារពេញលេញនៅឡើយ។ កូនត្រីនៅប្រើប្រាស់ថង់អាហារពណ៌លឿងជាប់នឹងពោះ ដែលជាប្រភពថាមពលដ៏សំខាន់សម្រាប់ការលូតលាស់។

***តារាងសង្ខេបអំពីការថែទាំ÷***

| អាយុកូនត្រី | សកម្មភាពសំខាន់ៗ | ការផ្តល់ចំណី |
|---|---|---|
| ថ្ងៃទី១ | ដកស៊ុមស្បៃសំណាញ់ចេញ និង សម្អាតសំបកពង | មិនផ្តល់ចំណី |
| ថ្ងៃទី២ | រក្សាទឹកឱ្យស្អាត ពិនិត្យកម្រិត អុកស៊ីសែន និងសីតុណ្ហភាពទឹក | មិនផ្តល់ចំណី |
| ថ្ងៃទី៣- ៧ | បូមកាកសំណល់បាតអាងពេល ព្រឹកមុនពេលផ្តល់ចំណី | ផ្តល់ចំណីរស់÷ ផ្តល់ប្រភេទចៃទឹក ឬ ម៉យណា (Moina) ៤-៦ដង/ថ្ងៃ |





### ៣.៣.៧. ការប្រមូលកូនត្រីទើបញាស់÷

កូនត្រីអណ្តែងទើបញាស់ ត្រូវបានរក្សាទុកនៅក្នុងអាងភ្ញាស់រយៈពេល ៣-៧ថ្ងៃ បន្ទាប់ពីត្រីប្រើថង់ចំណីបម្រុងអស់ ត្រីចាប់ផ្តើមរៀនស៊ីចំណីក្រៅ ទើបប្រមូលកូនត្រីថ្មីៗទៅដាក់នៅក្នុងអាងផ្សាំដែលរៀបចំទុកជាស្រេច។ កូនត្រីមានរូបរាងតូចឆ្មារដូចម្ជុល ពណ៌ខ្មៅ និងចូលចិត្តប្រមូលផ្តុំគ្នាជាដុំៗ ឬនៅផ្នែកងងឹតនៃជ្រុងអាង។ វិធីប្រមូលកូនត្រី កសិករត្រូវបង្ហូរទឹកចេញពីអាង ៤០-៥០% បន្ទាប់មកប្រើស្នៀដងកូនត្រីដោយប្រុងប្រយ័ត្នបំផុត ដើម្បីការពារកុំឱ្យកូនត្រីរបួស ឬងាប់ និងធ្វើការរាប់ចំនួនកូនត្រី *(វិធីសាស្រ្តរាប់កូនត្រីបានបង្ហាញនៅផ្នែកខាងលើ)*។

**ចំណុចគួរប្រុងប្រយ័ត្ន÷**

- **ផ្តល់ចំណីរស់÷** អាយុពី ៣- ៧ថ្ងៃ ត្រូវផ្តល់ចំណីរស់ (ប្លង់តុង ឬ Moina) ឱ្យបានគ្រប់គ្រាន់ (កសិករត្រូវផលិតសត្វប្លង់តុងរួចជាស្រេច និងផ្តល់ឱ្យកូនត្រីស៊ីឱ្យបានគ្រប់គ្រាន់)។
- **សុខភាពត្រី÷** ត្រូវរាប់ឱ្យបានលឿនបំផុត ដើម្បីកុំឱ្យកូនត្រីខ្វះអុកស៊ីហ្សែន។
- **សីតុណ្ហភាព÷** ទឹកដែលប្រើក្នុងកែវវាស់ និងទឹកក្នុងអាងត្រូវតែមានសីតុណ្ហភាពដូចគ្នា។
- **ការប៉ះទង្គិច÷** ប្រើស្នៀដែលទន់ល្អិតបំផុត បង្ការការដាច់រលាត់ស្បែក ឬរបួសដល់កូនត្រី។





## ៤. បច្ចេកទេសផ្សាំកូនត្រី

ដើម្បីទទួលបានកូនត្រីអណ្តែងពូជសម្រាប់ចិញ្ចឹមទៅជាត្រីសាច់ ត្រូវឆ្លងកាត់ពីរដំណាក់កាលគឺ ដំណាក់កាលកូនត្រីម្សៅ (Fry) អាយុចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី២១ និងដំណាក់កាលកូនត្រីពូជ (Fingerling) អាយុចាប់ពី២២ថ្ងៃ ដល់ថ្ងៃទី៤៥ អាចយកទៅចិញ្ចឹមបន្តជាត្រីអណ្តែងសាច់។

### ៤.១. ដំណាក់កាលកូនត្រីម្សៅ (Fry)

ជាដំណាក់កាលកូនត្រី អាយុចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី២១ ដែលត្រូវប្តូរពីការស៊ីចំណីរស់ (សត្វប្លង់តុង) មកស៊ីចំណីម្សៅ។ ការផ្សាំតែងធ្វើឡើងនៅក្នុងអាងស៊ីម៉ង់ត៍ ឬតង់ ឬធុងជ័រដែលបានរៀបចំរួចជាស្រេច។

- **ការផ្តល់ចំណី÷** សត្វប្លង់តុង និងចំណីម្សៅ មានកម្រិតប្រូតេអ៊ីនខ្ពស់ពី ៤០% ឡើងទៅ ផ្តល់ក្នុងបរិមាណចន្លោះពី ៥ - ៨% នៃទម្ងន់ខ្លួនសរុប និងឱ្យកូនត្រីស៊ីពី ៤ - ៦ដង/ថ្ងៃ ដើម្បីកាត់បន្ថយការស៊ីគ្នា និងបង្កើនការលូតលាស់។
- **ការគ្រប់គ្រងទឹក និងបរិស្ថាន÷** ផ្លាស់ប្តូរទឹកពី ២០ - ៣០% រាល់ថ្ងៃ ឬ២ថ្ងៃម្តង និងបូមកម្ទេចចំណីសល់ និងលាមកត្រីទៅបាត់អាងចេញឱ្យអស់។
- **រែងបំបែក÷** អាយុពី ១៥ ទៅ ២១ ថ្ងៃ ត្រូវរែងបំបែកទំហំត្រីលើកទី១។ បើមិនរែងបំបែកទេ កូនត្រីដែលធំជាងគេនឹងចាប់ផ្តើមស៊ីកូនត្រីដែលតូចជាង។
- **ដង់ស៊ីតេ÷** កម្រិតសមស្របចន្លោះពី ១,០០០ - ២,០០០ក្បាល / ម៉ែត្រការ៉េ

***តារាងសង្ខេបអំពីសកម្មភាពសំខាន់ៗ÷***

| អាយុ (ថ្ងៃ) | ប្រភេទចំណី | សកម្មភាពសំខាន់ៗ |
|---|---|---|
| ៨ - ១០ | សត្វប្លង់តុង និងម្សៅហ្មត់ | បូមកាកសំណល់បាតអាងរាល់ព្រឹក |
| ១១ - ១៤ | ម្សៅ ឬ គ្រាប់តូចបំផុត | ពិនិត្យទំហំត្រី បើខុសគ្នាខ្លាំងត្រូវត្រៀមរែងបំបែកកូនត្រី |
| ១៥ - ១៨ | គ្រាប់តូច (លេខ០.៥) | រែងបំបែកទំហំលើកទី១ និងពង្រីងអាង |
| ១៩ - ២១ | គ្រាប់តូច (លេខ១) | បន្ថែម Vitamin C ក្នុងចំណីដើម្បីពង្រឹងភាពស៊ាំ |





### ៤.២. ដំណាក់កាលកូនត្រីពូជ (Fingerling)

ជាដំណាក់កាលកូនត្រីអាយុចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី៤៥ ដែលមានភាពរឹងមាំ និងត្រៀមសម្រាប់យកទៅចិញ្ចឹមក្នុងស្រះត្រីសាច់។ ជាទូទៅ តែងយកកូនត្រីទៅផ្សាំក្នុងស្បៃហាប៉ា ឬបែរ ដាក់ក្នុងស្រះ ដើម្បីឱ្យកូនត្រីមានភាពស៊ាំនឹងបរិស្ថានទឹកស្រះ សីតុណ្ហភាពខាងក្រៅ និងមានភាពរឹងមាំ មុននឹងលែងចូលទៅក្នុងស្រះផ្ទាល់។

- **ការផ្តល់ចំណី÷** ប្រើចំណីគ្រាប់លេខ ២ ដែលមានកម្រិតប្រូតេអ៊ីនចន្លោះពី ៣០ - ៣៥% ក្នុងបរិមាណចន្លោះពី ៣ - ៥% នៃទម្ងន់ខ្លួន ផ្តល់ ៣ដង/ថ្ងៃ និងគួរលាយ Vitamin C ឬថ្នាំជំនួយថ្លើមទៅក្នុងចំណី ១ - ២ដង/សប្តាហ៍ ដើម្បីពង្រឹងភាពស៊ាំនឹងជំងឺ មុនពេលយកទៅចិញ្ចឹមសាច់។
- **ការរែងបំបែក÷** ត្រូវរែងបំបែករៀងរាល់ ៧ - ១០ថ្ងៃម្តង ដើម្បីតាមដានចំនួនកូនត្រីពិតប្រាកដ និងងាយស្រួលគ្រប់គ្រងចំណី។
- **ដង់ស៊ីតេ÷** គួររក្សាចន្លោះពី ២០០ - ៨០០ ក្បាល/ម៉ែត្រការ៉េ ទៅតាមទំហំកូនត្រី

***តារាងសង្ខេបអំពីសកម្មភាពសំខាន់ៗ÷***

| អាយុ (ថ្ងៃ) | ដង់ស៊ីតេ (ក្បាល/ម²) | ទំហំ/ប្រវែង (សង់ទីម៉ែត្រ) | សកម្មភាពសំខាន់ៗ |
|---|---|---|---|
| ២២ - ៣០ | ៨០០ | ៣ - ៤ | រែងបំបែកលើកទី២ និងតម្លើងចំណី (លេខ ១.២) |
| ៣១ - ៤០ | ៥០០ | ៥ - ៧ | ពិនិត្យសុខភាពកូនត្រី (ស្បែក ព្រុយ និងភ្នែក) |
| ៤១ - ៤៥ | ២០០ - ៣០០ | ៨ ឡើង | ត្រៀមដឹកជញ្ជូនទៅស្រះធំ ឬលក់ចេញជាកូនពូជ |





### ៤.៣. ប្រភេទជំងឺ និងការព្យាបាល

ដំណាក់កាលផ្សាំកូនត្រី គឺជាដំណាក់កាលដែលកូនត្រីងាយរងគ្រោះបំផុតដោយសារជំងឺ ពីព្រោះ កូនត្រីនៅតូច ប្រព័ន្ធការពាររាងកាយនៅខ្សោយ ចំណែកមជ្ឈដ្ឋានទឹកងាយនឹងប្រែប្រួល ដែលធ្វើឱ្យកូនត្រីងាយកើតមានជំងឺ។

#### ៤.៣.១. ប្រភេទជំងឺ

- **ជំងឺអុចស ឬស្រែង** (White Spot Disease/Ich)÷ បង្កឡើងដោយបរាសិត។ កូនត្រីមានអុចៗពណ៌សតូចៗលើស្បែក និងព្រុយ។ ត្រីហែលត្រដុសខ្លួននឹងជញ្ជាំងអាង ឬស្បៃ និងត្រីហែលវិលគ្មានទិសដៅ។
- **ជំងឺផ្សិត** (Fungal Infection)÷ ច្រើនកើតលើកូនត្រីដែលមានដំបៅ (ដោយសារខាំគ្នា ឬរែងបំបែកទំហំ)។ មានសណ្ឋានដូចសរសៃអំបោះពណ៌ស ឬដូចសំឡីដុះលើដងខ្លួន។
- **ជំងឺរលួយព្រុយ និងកន្ទុយ** (Fin and Tail Rot)÷ បង្កដោយបាក់តេរីក្នុងទឹកកខ្វក់។ ព្រុយ និងកន្ទុយត្រីចាប់ផ្ដើមរហែក និងរលួយជាលិកា។
- **ជំងឺប៉ោងពោះ ឬហើមពោះ**÷ បណ្ដាលមកពីការផ្ដល់ចំណីច្រើនហួសប្រមាណ ឬចំណីគ្មានគុណភាព ធ្វើឱ្យប្រព័ន្ធរំលាយអាហារមានបញ្ហា។





#### ៤.៣.២. វិធីបង្ការ

- **គ្រប់គ្រងគុណភាពទឹក**÷ ត្រូវប្ដូរទឹក និងបូមកាកសំណល់បាតអាងឱ្យបានទៀងទាត់។ កុំទុកឱ្យទឹកឡើងក្លិនស្អុយ ឬល្អក់ខ្លាំង។
- **ដង់ស៊ីតេត្រឹមត្រូវ**÷ កុំដាក់ត្រីណែនពេក ដែលនាំឱ្យត្រីស្ត្រេស និងខ្វះអុកស៊ីសែន។
- **អនាម័យ**÷ កញ្ច្រែងរែងត្រី ស្បៃជួសត្រីត្រូវលាងសម្អាត និងហាលថ្ងៃឱ្យស្ងួតក្រោយប្រើរួច។
- **ចំណី**÷ ផ្ដល់ចំណីសមល្មម (កុំឱ្យសល់) និងប្រើចំណីដែលមានប្រភពច្បាស់លាស់។
- **ការប្រើអំបិល**÷ ប្រើអំបិលគ្រួសក្នុងកម្រិតស្រាល (១-២ គីឡូក្រាម ក្នុងទឹក ១ ម៉ែត្រគូប) រាល់ពេលប្ដូរទឹក ដើម្បីជួយសម្លាប់មេរោគក្នុងទឹក។

#### ៤.៣.៣. វិធីព្យាបាល

ប្រសិនបើឃើញកូនត្រីចាប់ផ្ដើមមានរោគសញ្ញាជំងឺ ត្រូវអនុវត្តដូចខាងក្រោម÷

- **ផ្អាកផ្ដល់ចំណី÷** ពេលត្រីឈឺ ត្រូវបន្ថយឬផ្អាកផ្ដល់ចំណី ១-២ថ្ងៃ ដើម្បីកុំឱ្យទឹកកាន់តែខូច។
- **ប្ដូរទឹក÷** ប្ដូរទឹកស្អាត (ប្រហែល ៥០%) ដោយប្រុងប្រយ័ត្នបំផុតចំពោះសីតុណ្ហភាព។
- **ប្រើប្រាស់ថ្នាំ ឬសារធាតុព្យាបាល÷**
  - **អំបិលគ្រួស÷** ប្រើកម្រិត ៣-៥ គីឡូក្រាម/ម៉ែត្រគូប (សម្រាប់ករណីស្រាល)។
  - **ថ្នាំខៀវ (Methylene Blue)÷** ប្រើសម្រាប់ព្យាបាលជំងឺផ្សិត និងប៉ារ៉ាស៊ីត (ប្រើតាមការណែនាំលើផលិតផល)។
  - **ថ្នាំប៉ូតាស្យូម (Potassium Permanganate)÷** ប្រើសម្រាប់លាងសម្លាប់មេរោគលើដងខ្លួនត្រី (ត្រូវប្រើដោយប្រយ័ត្នបំផុតចំពោះកូនត្រីតូច)។
  - **វីតាមីន÷** លាយវីតាមីនស៊ី ក្នុងចំណី ដើម្បីជួយឱ្យត្រីមានកម្លាំងតស៊ូនឹងជំងឺ។

## ៥.ការប្រមូលផលកូនត្រីពូជ

### ៥.១. ការត្រៀមលក្ខណៈមុនប្រមូលផល

មុននឹងចាប់កូនត្រីពីស្បៃហាប៉ា ឬអាងផ្សាំទៅចិញ្ចឹមយកសាច់ ឬលក់បន្ដដល់អតិថិជនត្រូវអនុវត្តដូចខាងក្រោម÷

- **បង្អត់ចំណី÷** ត្រូវបង្អត់ចំណីកូនត្រីយ៉ាងតិច ១២ - ២៤ម៉ោង មុនពេលចាប់ ដើម្បីឱ្យពោះវៀនត្រីស្អាត កាត់បន្ថយការបញ្ចេញកាកសំណល់តាមផ្លូវ ដែលនាំឱ្យទឹកឆាប់ខូច និងខ្វះអុកស៊ីសែនក្នុងថង់។
- **ពិនិត្យសុខភាព÷** ធានាថាត្រីគ្មានជំងឺ គ្មានដំបៅ និងមានសកម្មភាពរហ័សរហួន។
- **ពេលវេលាប្រមូលផល÷** ត្រូវធ្វើនៅពេល ព្រឹកព្រលឹម ឬពេលល្ងាចត្រជាក់ ដើម្បីកាត់បន្ថយភាពស្ត្រេស (Stress) របស់ត្រីដោយសារកម្ដៅថ្ងៃ។

### ៥.២. បច្ចេកទេសចាប់ និងរាប់ចំនួន

- **ការប្រើឧបករណ៍÷** ប្រើស្នៀមុងក្រឡាញឹកទន់ ជៀសវាងការដាច់រលាត់ ឬរងរបួសព្រុយ។
- **វិធីសាស្ត្ររាប់÷** ប្រើវិធីថ្លឹងទម្ងន់ត្រី ១ ឬ ២គីឡូក្រាម និងរាប់ចំនួនកូនត្រី។ បន្ទាប់ពីដឹងចំនួនកូនត្រីក្នុងមួយគីឡូក្រាម នឹងអាចគណនារកចំនួនកូនត្រី។ ការរាប់ចំនួនត្រូវមានភាពរហ័ស និងមិនប៉ះពាល់ដល់សុខភាពត្រី។
- **ការថែមបង្គ្រប់÷** ជាទូទៅ ត្រូវថែមជូនអតិថិជនពី ៥% ទៅ ១០% ដើម្បីបង្ការការបាត់បង់ក្នុងពេលដឹកជញ្ជូន។

### ៥.៣. បច្ចេកទេសវេចខ្ចប់ និងដឹកជញ្ជូន

ការដឹកជញ្ជូនកូនត្រីអណ្តែងច្រើនធ្វើឡើងតាម ២ របៀប÷

- **ការច្រកថង់បូមអុកស៊ីសែន÷**
  - ដាក់ទឹកស្អាតប្រហែល ១/៣ នៃថង់ និងបញ្ចូលអុកស៊ីសែន ២/៣។
  - **ដង់ស៊ីតេក្នុងថង់÷** អាស្រ័យលើទំហំត្រី និងចម្ងាយផ្លូវ (ឧទាហរណ៍÷ កូនត្រី ៥-៧ សង់ទីម៉ែត្រ អាចដាក់បាន ១០០-២០០ ក្បាលក្នុងមួយថង់ធំ សម្រាប់ការធ្វើដំណើរ ៦-៨ ម៉ោង)។
- **ការប្រើធុងចំហ÷** ប្រើសម្រាប់ចម្ងាយផ្លូវជិតៗ ឬការដឹកជញ្ជូនក្នុងបរិមាណច្រើន។ ត្រូវត្រួតពិនិត្យសីតុណ្ហភាពទឹក កុំឱ្យក្តៅពេក។





## ៦-សេចក្តីសន្និដ្ឋាន

នៅក្នុងលក្ខខណ្ឌធម្មជាតិ ការបង្កាត់រវាងត្រីអណ្តែងអាហ្វ្រិច និងត្រីអណ្តែងលឿងកម្រនឹងកើតមាន និងមានអត្រារស់ទាប។ បច្ចេកទេសបង្កាត់ភ្ញាស់បែបសិប្បនិម្មិតគឺជាគន្លឹះដ៏សំខាន់ដើម្បីទទួលបានកូនត្រីដែលមានគុណភាព ធន់នឹងជំងឺ និងមានអត្រារស់ខ្ពស់។ ភាពជោគជ័យនៃអាជីវកម្មផលិតកូនត្រីពូជទាមទារឱ្យមានការយល់ដឹងស៊ីជម្រៅលើការជ្រើសរើសមេបាពូជ ការរៀបចំអាង ការប្រើប្រាស់អ័រម៉ូន និងការថែទាំកូនត្រីក្រោយពេលភ្ញាស់ (ការផ្សាំកូនត្រី)។

លើសពីនេះ ត្រីអណ្តែងកូនកាត់មានលក្ខណៈពិសេសគឺ មានការលូតលាស់លឿន ធន់នឹងជំងឺ និងងាយស្រួលចិញ្ចឹម។ ត្រីអណ្តែងក៏មានតម្លៃសេដ្ឋកិច្ចខ្ពស់ ឆ្លើយតបបានល្អទៅនឹងតម្រូវការទីផ្សារ និងជួយបង្កើនប្រាក់ចំណូលគ្រួសារកសិករ។

ឯកសារនេះ ត្រូវបានចងក្រងឡើងដើម្បីជាទុនគំនិតសម្រាប់កសិករក្នុងការបង្កើនទិន្នផល កាត់បន្ថយការចំណាយលើការទិញពូជត្រីពីខាងក្រៅ និងឈានទៅបង្កើតអាជីវកម្មខ្នាតតូច-មធ្យម ដែលរួមចំណែកដល់សេដ្ឋកិច្ចគ្រួសារកសិករនៅតាមជនបទ និងសេដ្ឋកិច្ចជាតិទាំងមូល។

## ប្រភពឯកសារសិក្សាស្រាវជ្រាវ÷


- បទពិសោធន៍ផ្ទាល់របស់កសិករផលិតកូនត្រីអណ្តែងកូនកាត់ នៅខេត្តកំពង់ចាម និងខេត្តបាត់ដំបង
- សៀវភៅណែនាំស្តីពីបច្ចេកទេសផលិតកូនត្រីពូជ (សហការរៀបចំដោយ÷ សាកលវិទ្យាល័យអ័រប៊ុន សាកលវិទ្យាល័យកាន់ធើ គម្រោងខាស់ និងរដ្ឋបាលជលផលកម្ពុជា https://elibrary.maff.gov.kh
- Tan-Fermin, J. D., Fermin, A. C., Bombeo, R. F., Evangelista, M. A. D., Catacutan, M. R., & Santiago, C. B. (2008). *Breeding and seed production of the Asian catfish Clarias macrocephalus (Gunther)* (Aquaculture Extension Manual No. 40). Southeast Asian Fisheries Development Center, Aquaculture Department.
- TS.Duong Nhut Long,2013. Ky Thuat nuoi ca tre-Dai hoc Can Tho https://tepbac.com/technical/full/39/ky-thuat-nuoi-ca-tre
- Duong, T. Y., Nguyen, T. T., Nguyen, V. N., & Dang, T. P. (2020). Tăng trưởng của cá giống trê vàng (Clarias macrocephalus) lai giữa ba nguồn cá bố mẹ. Đại học Cần Thơ. https://doi.org/10.22144/ctu.jsi.2020.044
- Lê, V. D. (2012). Nghiên cứu sản xuất giống cá trê lai (Clarias gariepinus x C. macrocephalus). Đại học Huế. https://hueuni.edu.vn/portal/data/doc/tapchi/61.pdf
- Tram, N. D. Q. (2010). Evaluation of local feed resources for hybrid catfish (Clarias macrocephalus x C. gariepinus) in smallholder fish farming systems in Vietnam. https://pub.epsilon.slu.se/2366/
- Trại Giống F1. (n.d.). *Cá trê lai giống lớn nhanh, dễ nuôi, đầu tư hiệu quả.* https://traigiongf1.com/san-pham/ca-tre-lai-giong/
- Trại Giống F1. (n.d.). Kỹ thuật sinh sản cá trê vàng và ương cá trê vàng bột. https://traigiongf1.com/ky-thuat-sinh-san-ca-tre-vang-va-uong-ca-tre-vang-bot/